**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

លេខ ....៩០............ប- បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩។

ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ -សាលក្រមប្រកាសជាសាធារណៈ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០២០។

សំណុំរឿងរដ្ឋប្បវេណី

លេខ ១២៨២

ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩

-លោក [redacted] ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ។

-លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ។

**រវាង** ដើមចោទ **ក្រុមហ៊ុន** [redacted] ជាក្រុមហ៊ុនបង្កើតឡើងតាមច្បាប់នៃប្រទេសសិង្ហបុរី មានលេខចុះបញ្ជី [redacted] និងអាសយដ្ឋានចុះបញ្ជីនៅ [redacted] តំណាងដោយអាណត្តិលោកមេធាវី [redacted]

**និង** ចុងចម្លើយ **ក្រុមហ៊ុន** [redacted] មានអាសយដ្ឋានចុះបញ្ជីនៅ [redacted] តំណាងដោយឈ្មោះ [redacted] ជាប្រធានក្រុមប្រឹក្សាភិបាល និងឈ្មោះ [redacted] ជាអភិបាល។

**ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:** ប្តឹងសុំឱ្យតុលាការចេញសាលក្រមសម្រេចបង្គាប់ឱ្យចុងចម្លើយក្រុមហ៊ុន [redacted] សងនូវ:

១-ប្រាក់ជំពាក់ចំនួន ៤៣,២៦២.២៥(បួនម៉ឺនបីពាន់ ពីររយហុកសិបពីរ និងម្ភៃប្រាំសេនគត់)ដុល្លារអាមេរិក។

២-ការប្រាក់យឺតយ៉ាវចំនួន ១.៥% ក្នុងមួយខែ នៃប្រាក់ដើម គិតចាប់ពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។

៣-សំណងការខូចខាតចំនួន ២០,០០០(ពីរម៉ឺន)ដុល្លារអាមេរិក។

៤-សុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

## អង្គហេតុ និងចំណុចវិវាទ

### ១-អង្គហេតុ:

-ក្នុងរឿងក្តីនេះ គឺដើមចោទក្រុមហ៊ុន [redacted] បានរកស៊ីលក់ភេសជ្ជៈមានរសជាតិដូចជា: ផ្លែស្វាយ ស្ត្របឺរី និងផ្លែឈើចម្រុះ និងជាអ្នកផ្គត់ផ្គង់ភេសជ្ជៈឱ្យទៅចុងចម្លើយក្រុមហ៊ុន [redacted] តាមការបញ្ជាទិញទំនិញរបស់ចុងចម្លើយ។ រាល់ការបញ្ជាទិញ និងការផ្តល់ការផ្គត់ផ្គង់ភេសជ្ជៈឱ្យចុងចម្លើយ គឺដើមចោទបានចេញវិក័យបត្រចំនួន ០៤គឺវិក័យប័ត្រលេខ១៥១២១២១៧ RI ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ មានទឹកប្រាក់ដែលចំនួន ១៣,៩៥៧.២៥(មួយម៉ឺនបីពាន់ ប្រាំបួនរយហាសិបប្រាំពីរ និងម្ភៃប្រាំសេនគត់)ដុល្លារអាមេរិក,វិក័យប័ត្រលេខ១៥១២៧៩៩២ RI មានទឹកប្រាក់ចំនួន ១៤,១៥៥(មួយម៉ឺនបួនពាន់ មួយរយហាសិបប្រាំ)ដុល្លារអាមេរិក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦, វិក័យប័ត្រលេខ១៥១៣៤០៧៦ RI មានទឹកប្រាក់ចំនួន ១៤,៦៥០(មួយម៉ឺនបួនពាន់ ប្រាំមួយរយហាសិប)ដុល្លារអាមេរិក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ និងវិក័យប័ត្រលេខ៣៣៨១FD មានទឹកប្រាក់ចំនួន ៥០០(ប្រាំរយ)ដុល្លារអាមេរិក ចុះ



Scanned with CamScanner

ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦។ ប៉ុន្តែ ចាប់តាំងពីពេលបញ្ជាទិញទំនិញក្នុងឆ្នាំ២០១៦ រហូតមកដល់សព្វថ្ងៃនេះ គឺចុងចម្លើយមិនទាន់បានទូទាត់ប្រាក់មកឱ្យដើមចោទនោះទេ គឺមានទឹកប្រាក់សរុបចំនួន៤៣,២៦២.២៥(បួនម៉ឺនបីពាន់ ពីររយហុកសិបពីរ និងម្ភៃប្រាំសេនគត់)ដុល្លារអាមេរិក។ ក្រោយមក ចុងចម្លើយបានទទួលស្គាល់ និងស្នើធ្វើការបង់ប្រាក់បណ្ដាក់ប្រចាំខែចំនួន ១០,០០០(មួយម៉ឺន)ដុល្លាអាមេរិក រហូតដល់ប្រាក់ជំពាក់ត្រូវបានទូទាត់អស់។ ប៉ុន្តែ ចុងចម្លើយនៅតែបំពានការសន្យា និងធ្វើការដោះសារជាច្រើនដង ដែលជាហេតុធ្វើឱ្យដើមចោទបានដាក់ពាក្យបណ្ដឹង ដើម្បីប្ដឹងទាមទារប្រាក់ និងការពារផលប្រយោជន៍របស់ដើមចោទ។

## ២-សេចក្ដីថ្លែងការណ៍របស់គូភាគី

ក-តំណាងដោយអាណត្តិឱ្យដើមចោទ **ក្រុមហ៊ុន** [redacted] លោកមេធាវី [redacted] និងលោកស្រីមេធាវី [redacted] បានថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: ពួកខ្លួនសុំរក្សាការទាមទារដូចមាននៅក្នុងសេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ នៅដដែល។ មូលហេតុដែលពួកខ្លួនប្ដឹងសុំឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយ ក្រុមហ៊ុន [redacted] សងប្រាក់ចំនួន ៤៣,២៦២.២៥(បួនម៉ឺនបីពាន់ ពីររយហុកសិបពីរ និងម្ភៃប្រាំសេនគត់)ដុល្លារអាមេរិក,សងការប្រាក់យឺតយ៉ាវចំនួន ១.៥% ក្នុងមួយខែ នៃប្រាក់ដើម គិតចាប់ពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន,សំណងការខូចខាតចំនួន ២០,០០០(ពីរម៉ឺន)ដុល្លារអាមេរិក ដោយហេតុថា: ក្នុងឆ្នាំ២០១៦ ក្រុមហ៊ុន [redacted] បានបញ្ជាទិញទំនិញជាប្រភេទភេសជ្ជៈមានរស់ជាតិដូចជា ផ្លែស្វាយ ស្ត្របឺរី និងផ្លែឈើចម្រុះ ពីក្រុមហ៊ុន [redacted] ហើយក្រុមហ៊ុន [redacted] បានផ្គត់ផ្គង់ និងដឹកជញ្ជូនទំនិញទៅឱ្យក្រុមហ៊ុន [redacted] ប៉ុន្តែក្រុមហ៊ុន [redacted] មិនទាន់ទូទាត់ប្រាក់ចំពោះវិក័យប័ត្រចំនួន ០៤ គឺវិក័យប័ត្រលេខ១៥១២២១៧ RI ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ មានទឹកប្រាក់ដែលមិនទាន់ទូទាត់ចំនួន ១៣,៩៥៧.២៥(មួយម៉ឺនបីពាន់ ប្រាំបួនរយហាសិបប្រាំពីរ និងម្ភៃប្រាំសេនគត់)ដុល្លារអាមេរិក,វិក័យប័ត្រលេខ១៥១២៧៩៩២ RI មានទឹកប្រាក់ដែលមិនទាន់ទូទាត់ចំនួន ១៤,១៥៥(មួយម៉ឺនបួនពាន់ មួយរយហាសិបប្រាំ)ដុល្លារអាមេរិក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦,វិក័យប័ត្រលេខ១៥១៣៤០៧៦ RI មានទឹកប្រាក់ដែលមិនទាន់ទូទាត់ចំនួន ១៤,៦៥០(មួយម៉ឺនបួនពាន់ ប្រាំមួយរយហាសិប)ដុល្លារអាមេរិកចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ និងវិក័យប័ត្រលេខ៣៣៨១FD មានទឹកប្រាក់ដែលមិនទាន់ទូទាត់ចំនួន ៥០០(ប្រាំរយ)ដុល្លាអាមេរិក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រុមហ៊ុន [redacted] ដូចនេះ ទឹកប្រាក់មិនទាន់ទូទាត់ដោយចុងចម្លើយមានចំនួនសរុប ៤៣, ២៦២.២៥(បួនម៉ឺនបីពាន់ ពីររយហុកសិបពីរ និងម្ភៃប្រាំសេនគត់)ដុល្លារអាមេរិក។ ក្រោយមកចាប់ពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ដល់ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ក្រុមហ៊ុន [redacted] បានផ្ញើអ៊ីម៉ែលឆ្លើយឆ្លងជាច្រើនដងទៅចុងចម្លើយដើម្បីទាមទារប្រាក់ចំនួន ៤៣,២៦២.២៥(បួនម៉ឺនបីពាន់ ពីររយហុកសិបពីរ និងម្ភៃប្រាំសេនគត់)ដុល្លារអាមេរិក ដែលក្រុមហ៊ុន [redacted] មិនទាន់ទូទាត់ ហើយនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ក្រុមហ៊ុន [redacted] ទទួលស្គាល់ និងស្នើធ្វើការបង់ប្រាក់បណ្ដាក់ប្រចាំខែចំនួន ១០,០០០(មួយម៉ឺន)ដុល្លាអាមេរិក ដោយចាប់ផ្ដើមពីខែមករា ឆ្នាំ២០១៧ រហូតដល់ប្រាក់ជំពាក់ត្រូវបានទូទាត់អស់។ ប៉ុន្តែ ក្រុមហ៊ុន [redacted] នៅតែបំពានការសន្យា និងធ្វើការដោះសារជាច្រើនដង ដែលជាហេតុធ្វើឱ្យក្រុមហ៊ុន [redacted] បានដាក់ពាក្យបណ្ដឹង ដើម្បីប្ដឹងទាមទារប្រាក់ និងការពារផលប្រយោជន៍របស់ក្រុមហ៊ុន។

<u>សំណូមពរ:</u> សុំឱ្យតុលាការចេញសាលក្រមសម្រេចបង្គាប់ឱ្យចុងចម្លើយក្រុមហ៊ុន [redacted]ូវ:

១-សងប្រាក់ចំនួន ៤៣,២៦២.២៥(បួនម៉ឺនបីពាន់ ពីររយហុកសិបពីរ និងម្ភៃប្រាំសេនគត់)ដុល្លារអាមេរិក។

២-សងការប្រាក់យឺតយ៉ាវចំនួន ១.៥% ក្នុងមួយខែ នៃប្រាក់ដើម គិតចាប់ពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។

៣-សងសំណងការខូចខាតចំនួន ២០,០០០(ពីរម៉ឺន)ដុល្លារអាមេរិក។

៤-សុំអនុវត្តសាលក្រមជាបណ្ដោះអាសន្ន។

៥-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

**ខ**-តំណាងឱ្យចុងចម្លើយ [redacted] លោក [redacted] និងលោក [redacted] (អវត្តមាន) ដោយបានទទួលដំណឹងពីការចូលរួមពីនីតិវិធីសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង០៩ព្រឹក តាមការបញ្ជូនដីកាកោះចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ និងការចុះផ្សាយជាសាធារណៈលើទំព័រ៥ នៃកាសែតរស្មីកម្ពុជា ឆ្នាំទី២៧ លេខ៨១០០ ថ្ងៃព្រហស្បតិ៍ ទី១២ ខែធ្នូ ឆ្នាំ២០១៩ ត្រឹមត្រូវរួចហើយ។

**៣-__ចំណុចវិវាទនៃអង្គហេតុ:__** គ្មាន។

## __ការសំអាងហេតុ__

១-តាមសេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ និងបណ្ណាវិក័យប័ត្រទិញលក់ភេសជ្ជៈចំនួន០៤ ដែលបានធ្វើឡើងរវាងដើមចោទ និងចុងចម្លើយមានភាពស៊ីសង្វាក់ជាមួយភស្តុតាងជាឯកសារនានា បញ្ជាក់ថា: ដើមចោទ និងចុងចម្លើយពិតជាបានបង្កើតកិច្ចសន្យាដោយសារសំណើ និងស្វីការ តាមឆន្ទៈព្រមព្រៀងប្រាកដមែន។

២-តាមពាក្យបណ្ដឹង ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ និងសេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានប្ដឹងទាមទារឱ្យចុងចម្លើយសងប្រាក់ជំពាក់ថ្លៃភេសជ្ជៈសរុបចំនួន៤៣,២៦២.២៥(បួនម៉ឺនបីពាន់ ពីររយហុកសិបពីរ និងម្ភៃប្រាំសេនគត់)ដុល្លារអាមេរិក។ ប៉ុន្តែ ចុងចម្លើយបានអវត្តមាននៅដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងអវត្តមាននៅដំណាក់កាលនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ទោះបីបានទទួលដំណឹងតាមការបញ្ជូនដីកាកោះ និងការចុះផ្សាយលើទំព័រកាសែតរស្មីកម្ពុជា ត្រឹមត្រូវតាមនីតិវិធីរួចហើយ ចុងចម្លើយក៏បានទទួលនូវខ្លឹមសារនៃសេចក្ដីថ្លែងការណ៍របស់ដើមចោទ នៅដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រឹមត្រូវតាមនីតិវិធី។ ដូច្នេះការមិនបានបង្ហាញខ្លួននៅដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ គឺអាចចាត់ទុកចុងចម្លើយបានសារភាពតាមសេចក្ដីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុ។ តាមមាត្រា២០១ និងមាត្រា២០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៣-ដើមចោទប្ដឹងសុំឱ្យចុងចម្លើយសងការប្រាក់យឺតយ៉ាវចំនួន ១.៥% ក្នុងមួយខែ នៃប្រាក់ដើម គិតចាប់ពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។ ប៉ុន្តែ តាមការពិនិត្យភស្តុតាងជាឯកសារលើលិខិតទាមទារប្រាក់ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ និងលិខិតនានា គឺមិនមានភស្តុតាងបញ្ជាក់ថា: ចុងចម្លើយយល់ព្រមសងការប្រាក់យឺតយ៉ាវចំនួន១.៥% គិតចាប់ពីថ្ងៃទី ២៨ ខែមករា ឆ្នាំ២០១៩ មកឱ្យដើមចោទនោះទេ។ គប្បី តុលាការមិនសម្រេចតាមការប្ដឹងទាមទាររបស់ដើមចោទលើចំណុចនេះទេ។ម្យ៉ាងវិញទៀត ដើមចោទបានប្ដឹងទាមទារឱ្យសហចុងចម្លើយសងសំណងការខូចខាតចំនួន ២០,០០០(ពីរម៉ឺន)ដុល្លារអាមេរិក។ គប្បី តុលាការពិចារណា។

៤-ដើមចោទប្ដឹងសុំឱ្យតុលាការប្រកាសឱ្យសាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបាន។ ប៉ុន្តែ គ្មានហេតុផលណាមួយដែលចុងចម្លើយអាចគេចផុតពីការមិនបំពេញកាតព្វកិច្ច ឬមានការលំបាកដល់ដើមចោទក្នុងការអនុវត្តដោយបង្ខំ

តាមអំណាចសាលក្រម សាលដីកាស្ថាពររបស់តុលាការបានឡើយ។ គប្បី តុលាការមិនសម្រេចតាមការប្តឹងទាមទាររបស់ដើមចោទលើចំណុចនេះទេ។

៥-ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់អ្នកចាញ់ក្តី។

**សេចក្តីសម្រេចបញ្ចប់**

១-ទទួលស្គាល់ការប្តឹងទាមទាររបស់ដើមចោទដោយបង្គាប់ឲ្យចុងចម្លើយ [redacted] តំណាងដោយឈ្មោះ [redacted] ជាប្រធានក្រុមប្រឹក្សាភិបាល និងឈ្មោះ [redacted] ជាអភិបាល សងប្រាក់ទៅឲ្យដើមចោទ **ក្រុមហ៊ុន F&N Foods Pte Ltd** តំណាងដោយអាណត្តិលោកមេធាវី [redacted] និង លោកស្រីមេធាវី [redacted] ដូចខាងក្រោម:

ក-សងប្រាក់ជំពាក់ចំនួន ៤៣,២៦២.២៥(បួនម៉ឺនបីពាន់ ពីររយហុកសិបពីរ និងម្ភៃប្រាំសេនគត់)ដុល្លារអាមេរិក។

ខ-សងសំណងការខូចខាតចំនួន ២០,០០០,០០០(ម្ភៃលាន)រៀល។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**ចៅក្រម**

**ហត្ថលេខា និងត្រា:** [redacted]

---

**បានឃើញ**

**ចៅក្រម**

[redacted]

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១៣រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]